# មូលនិធិសង្គ្រោះអាជីវកម្មខ្នាតតូចក្នុងតំបន់ LA : ការណែនាំអំពីការដាក់ពាក្យ

department of economic opportunity
COUNTY OF LOS ANGELES

ECONOMIC & WORKFORCE DEVELOPMENT DEPARTMENT
LOS ANGELES

department of economic opportunity
COUNTY OF LOS ANGELES

ECONOMIC & WORKFORCE DEVELOPMENT DEPARTMENT LOS ANGELES

# ទិដ្ឋភាពទូទៅនៃកម្មវិធី

មូលនិធិសង្គ្រោះអាជីវកម្មខ្នាតតូចរបស់ LA ក្នុងស្រុកបានផ្តល់ថវិកាពីចន្លោះ 2000 ដុល្លារដល់ 25.000 ដុល្លារសម្រាប់ផ្តល់ជូនជួយល់អាជីវកម្មខ្នាតតូចនិងអង្គភាពមិនទទួលប្រាក់ចំណូល ដែលបានទទួលរងផលប៉ះពាល់ដោយខ្យល់ព្យុះនិង ភ្លើងឆេះព្រៃ នៅក្នុងទីក្រុង ឡូស អេនជេឡេស។ ថវិកាទាំងនេះបង្កើតឡើងក្នុងគោលបំណងជួយស្តារដល់ក្រុមហ៊ុនអោយបានក្រោកឡើងវិញក្រោយការរងគ្រោះមហន្តរាយនិងអាចបន្តប្រតិបត្តិការទៅមុខ។

ពាក្យស្នើសុំនឹងបើកចាប់ពីថ្ងៃទី 6 ខែកុម្ភៈឆ្នាំ 2025 ដល់ថ្ងៃទី 24 ខែកុម្ភៈឆ្នាំ 2025 ។ លោកអ្នកគ្រាន់តែគ្រាន់ តែធ្វើការ ចំណាយពេលចន្លោះពី 20 ទៅ 30 នាទីដើម្បីធ្វើការបំពេញពាក្យស្នើសុំនេះ ហើយ លោកអ្នក ក៏អាចធ្វើ ការរក្សាទុកពាក្យស្នើសុំនេះបានសម្រាប់កែសម្រួលនៅពេលក្រោយប្រសិនបើចាំបាច់។

## ព័ត៌មានលម្អិតអំពីការផ្ដល់មូលនិធិនិងដំណាក់កាលផ្សេងៗ

បរិមាណជំនួយអាស្រ័យលើប្រភេទនិងស្ថានភាពធ្ងន់ធ្ងរនៃការរងផលប៉ះពាល់

$25,000 – 25,000 ដុល្លារ - សម្រាប់អាជីវកម្មឥដ្ឋ - និងឡបាយអដែលត្រូវបានបំផ្លាញទាំងស្រុង។

$20,000 – សម្រាប់អាជីវកម្មដែលខូចខាតជាចំណែក

$15,000 – សម្រាប់អាជីវកម្មដែលខាតបង់ដោយមិនទទួលប្រាចំណូលតែប៉ុណ្ណោះ។

$5,000 – សម្រាប់អាជីវកម្មនៅតាមផ្ទះនិងអ្នកម៉ៅការឯករាជ្យដែលមានប្រាក់ចំណូលនិងការខាតបង់ / ការបាត់បង់ឧបករណ៍ / សម្ភារៈ។

$2,000 – សម្រាប់អាជីវកម្មនៅតាមផ្ទះនិងអ្នកម៉ៅការឯករាជ្យដែលបានបាត់បង់តែប្រាក់ចំណូលប៉ុណ្ណោះ។

ការផ្ដល់មូលនិធិបន្ថែមអាចមានផ្ដល់ជូននៅក្នុងដំណាក់កាលបន្តបន្ទាប់។

## ទីតាំងកន្លែងដាក់ពាក្យស្នើសុំ

លោកអ្នកអាចដាក់ពាក្យបានតាមអនឡាញនៅលើគេហទំព័រៈ

lacbusinesses.aidkit.org/apply ឬទទួលបានជំនួយដោយផ្ទាល់នៅ:

ការិយាល័យ តំបន់ LA ដែលជាគំនិតផ្តួចផ្តើមរបស់សេដ្ឋកិច្ចអាជីវកម្មខ្នាតតូច (EMI)

មជ្ឈមណ្ឌលប្រភពធនធាន តំបន់ LA

មជ្ឈមណ្ឌលស្តារគ្រោះមហន្តរាយក្នុងតំបន់

មជ្ឈមណ្ឌលអភិវឌ្ឍន៍អាជីវកម្មខ្នាតតូច (SBDCs)

សម្រាប់ទីតាំងនិងការគាំទ្រទស្សនា

lacbusinesses.aidkit.org/sl/taproviders ។

## លក្ខណដែលអាចទទួលបាន

ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់លោកអ្នកត្រូវតែៈ

✔ជាម្ចាស់អាជីវកម្មខ្នាតតូចមួយឬជាអង្គភាពមិនរកប្រាក់ចំណេញនៅតំបន់ Los Angeles ។

✔មាននិយោជិក 100 នាក់ឬតិចជាងនេះ។

✔មានប្រាក់ចំណូលប្រចាំឆ្នាំ ចាប់ពី 6 លានដុល្លារឬតិចជាងនេះ។

✔បានទទួលការបំផ្លាញទាំងស្រុងឬខូចខាតដល់ទីតាំងពាណិជ្ជកម្មរបស់អាជីវកម្មដោយខូចខាតសម្ភារៈការបាត់បង់ឧបករណ៍ឬការធ្លាក់ចុះប្រាក់ចំណូលដោយសារគ្រោះមហន្តរាយ។

✔អាជីវកម្មនៅមានជំហរល្អជាមួយភ្នាក់ងាររដ្ឋាភិបាល (អាជ្ញាប័ណ្ណអាជីវកម្មត្រឹមត្រូវតាមការអនុលោមពន្ធជាដើម) ។

អាទិភាពនឹងត្រូវបានផ្ដល់ឱ្យអាជីវកម្មដែលរងផលប៉ះពាល់ស្ថានភាពធ្ងនធ្ងរ។

ប្រសិនបើការដាក់ពាក្យមានចំនួនលើសពីមូលនិធិដែលបានផ្ដល់ជូន យើងនឹងប្រើប្រាស់ប្រព័ន្ធចាប់ឆ្នោត ។

## ឯកសារចាំបាច់និងព័ត៌មានដែលយើងត្រូវការត្រួតពិនិត្យៈ

- ផ្នែកនីមួយៗនៃការដាក់ពាក្យតម្រូវឱ្យលោកអ្នកមានឯកសារជាក់លាក់ដែលបានគូសបញ្ជាក់នៅពេលក្រោយក្នុងសៀវភៅណែនាំនេះ។
- សូមប្រាកដថាឈ្មោះអាជីវកម្មនិងព័ត៌មានលម្អិតសំខាន់ៗរបស់លោកអ្នកអាចមើលឃើញច្បាស់ល្អ។
- ប្រសិនបើលោកអ្នកមិនមានឯកសារទេ ការដាក់ពាក្យនឹងត្រូវបានបញ្ឈប់។
- លោកអ្នកត្រូវតែមានឯកសារចាំបាច់ទាំងអស់ដើម្បីបំពេញពាក្យស្នើសុំនេះ។
- ប្រសិនបើលោកអ្នកមានចង្ងល់ផ្សេងៗឬមិនច្បាស់អំពីឯកសារ លោកអ្នកអញ្ជើញមកកាន់មជ្ឈមណ្ឌលជំនួយព័ត៌មានអាជីវកម្មប៉ុន្តែពាក្យស្នើសុំរបស់លោកអ្នកមិនអនុញ្ញាតអោយលោកអ្នកបន្តបំពេញពាក្យនោះទេ លុះត្រាតែលោកអ្នកបានរបង្ហោះឯកសារដែលត្រូវការចាំបាច់នៅផ្នែកនីមួយៗ។

ដើម្បីមើលបញ្ជីឯកសារចាំបាច់ទាំងអស់ សូមចុច នៅទីនេះ។

# របៀបបំពេញពាក្យស្នើសុំ

department of economic opportunity
COUNTY OF LOS ANGELES

ECONOMIC & WORKFORCE DEVELOPMENT DEPARTMENT
LOS ANGELES

## របៀបចាប់ផ្តើមលើពាក្យស្នើសុំ៖

- សូមសាកសួរនៅកាន់គេហទំព័រ lacbusinesses.aidkit.org/apply ឬសាកសួរនៅកាន់មជ្ឈមណ្ឌលការងារក្នុងតំបន់ឬមជ្ឈមណ្ឌលស្តារគ្រោះមហន្តរាយសម្រាប់ជំនួយបុគ្គល។
- បំពេញជំហាននីមួយៗក្នុងពាក្យស្នើសុំដែលលោកអ្នកអាចធ្វើតាមបាន ដើម្បីចាប់ផ្តើមបំពេញពាក្យសស្នើសុំឬរក្សាទុកពាក្យស្នើសុំដើម្បីត្រឡប់មកធ្វើនៅពេលក្រោយ។



# ជំហាននៃការបំពេញពាក្យស្នើសុំ

សូមអនុវត្តតាមការណែនាំតាមជំហាននីមួយៗ
ដើម្បីបំពេញពាក្យស្នើសុំរបស់លោកអ្នកឱ្យបានត្រឹមត្រូវ

department of economic opportunity
COUNTY OF LOS ANGELES

ECONOMIC & WORKFORCE DEVELOPMENT DEPARTMENT LOS ANGELES

# ដំណាក់កាលទី 1៖ ការស្វាគមន៍

ជ្រើសយកភាសាដែលលោកអ្នកពេញចិត្ត (ភាសាអង់គ្លេសឬភាសាអេស្ប៉ាញ) ដើម្បីធ្វើការបំពេញពាក្យស្នើសុំ។

ប្រសិនបើលោកអ្នកត្រូវការជំនួយក្នុងភាសាក្រៅពីភាសាអង់គ្លេសឬអេស្ប៉ាញ សូមទៅកាន់ការិយាល័យអាជីវកម្មខ្នាតតូចក្នុងក្រុង ឡូស អេនជីឡេស ដែលជាដៃគូផ្តួចផ្តើមផ្នែកសេដ្ឋកិច្ច (EMI) ឬមជ្ឈមណ្ឌលប្រភពអាជីវកម្មក្នុងទីក្រុង ឡូស អេនជីឡេស សម្រាប់ជំនួយផ្សេងៗ។

សម្រាប់ព័ត៌មានពីទីតាំងសូមចូលទៅកាន់គេហទំព័រ

lacbusinesses.aidkit.org/sl/taproviders.



# ជំហានទី 2៖ សំណួរដែលត្រូវបានសួរភាគច្រើន (FAQS)

ត្រួតពិនិត្យលើសំណួរដែលត្រូវបានសួរភាគច្រើន (FAQs) ជាជំនួយរៀបចំលោកអ្នកក្នុងដំណើរការនៃពាក្យស្នើសុំ។

លោកអ្នកអាចស្វែងរកសំណួរដែលត្រូវបានសួរភាគច្រើននៅតំណភ្ជាប់ខាងក្រោម

www.lacbusinesses.aidkit.org/p/faq

សូមចូលទៅកាន់ឯកសារនិងបញ្ជីពិនិត្យផ្សេងៗ នៅទីនេះ។



## ជំហានទី 3៖ ព័ត៍មានទំនាក់ទំនង

សូមធ្វើការផ្តល់នូវព័ត៍មានទំនាក់ទំនងសំខាន់ៗ

- សូមផ្តល់ឈ្មោះតាមអត្តសញ្ញាណឯកសារច្បាប់ដែលចេញដោយរដ្ឋាភិបាល។ ចំណាំ៖ លោកអ្នកត្រូវតែជាម្ចាស់អាជីវកម្ម ឬ ម្ចាស់អង្គភាពមិនរកប្រាក់កម្រៃ ឬជាម្ចាស់ក្រុមហ៊ុន។
- សូមបញ្ចូលថ្ងៃខែឆ្នាំកំណើត (ត្រូវតែមានអាយុ 18 ឆ្នាំ ឬលើសពី 18 ឆ្នាំ).
- សូមផ្តល់នូវលេខទូរសព្ទរបស់លោកអ្នក (សម្រាប់ ការទំនាក់ទំនង និងការផ្ទៀងផ្ទាត់ព័ត៍មាន).
- សូមបញ្ចូលអ៊ីម៉ែល (លោកអ្នកនឹងទទួលបានព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាពនៅទីនេះ)។

- សូមចំណាំ ប្រសិនបើលោកអ្នកត្រឡប់មកបន្តមកបំពេញពាក្យស្នើសុំ សូមចុចលើពាក្យ “Resume” ក្នុងពាក្យស្នើសុំ បន្ទាប់ពីបានបញ្ចូល នូវព័ត៍មានទំនាក់ទំនង។



## បន្តទៅក្នុងជំហានទី 3...

លោកអ្នកនឹងទាមទារអោយធ្វើការផ្ទៀងផ្ទាត់លើព័ត៌មានទំនាក់ទំនង ដែលលោកអ្នកបានបញ្ចូល។ លោកអ្នកនឹង ទទួលបានលេខសម្ងាត់ ដែលបានផ្ញើទៅកាន់អ៊ីម៉ែល និង លេខទូរសព្ទរបស់លោកអ្នក។









## ជំហានទី 4៖ កិច្ចព្រមព្រៀងក្នុងការដាក់ពាក្យ

ត្រួតពិនិត្យឡើងវិញ ហើយទទួលយកគោលការណ៍ឯកជនភាពទិន្នន័យរបស់កស្នើសុំ។

# Consent to Apply

**Data Privacy:**

- I authorize AidKit, Southern California Grantmakers, Los Angeles County, and the City of Los Angeles to collect and use my personal information for the purpose of verification and fraud prevention, program communications, eligibility determination, payment processing, evaluation of program impact, and improvement of the AidKit platform and future City of Los Angeles and County programming.
- I authorize Southern California Grantmakers, AidKit, Los Angeles County, and the City of Los Angeles to use my contact information to reach out with additional information, programs, and services related to the LA Region 2025 Windstorm and Wildfires.
- Personal information can include identity information (name, government ID, image/video), contact details, demographics and employment data or my financial information.
- This information may b identity verification ser the rules of applicable
- I understand that my da party partners and that be used to provide the application, improve fe to this application and t recovery services. I unc accordance with this p purposes or sold to ext

**My Rights:**

- I understand that I have the right to access/correct/delete my data by contacting privacy@aidkit.cloud.
- I can withdraw this consent at any time by contacting the same email address and acknowledge that such withdrawal may affect my participation in a program.
- I have a right to be notified in case of any data breach.
- I understand that AidKit will not sell my data under any circumstances.

*By moving forward with this application, I accept these terms and agree to receive program-related communications.*

# ជំហានទី 5: ជំនួយសម្រាប់ពាក្យស្នើសុំ

សូមបញ្ជាក់ថាតើលោកអ្នកត្រូវការជំនួយពីភ្នាក់ងារផ្តល់ព័ត៌មាន ឬ លោកអ្នកចង់
បំពេញពាក្យស្នើសុំដោយខ្លួនឯង។

ប្រសិនបើលោកអ្នកត្រូវការជំនួយដោយជួបបុគ្គលិកជំនួយផ្ទាល់ នោះពាក្យស្នើសុំនឹងត្រូវបានបញ្ឈប់។ នៅពេលដែលលោកចង់បន្តក្នុងការបំពេញពាក្យ មិនថាទៅកន្លែងដោយផ្ទាល់ឬបំពេញពាក្យដោយខ្លួនអ្នកផ្ទាល់ទេ លោកអ្នកគ្រាន់តែចូលគណនីលោកអ្នកហើយធ្វើការកែប្រែដើម្បីបន្តការបំពេញពាក្យស្នើសុំ។ ប្រសិនបើលោកអ្នកទៅទីតាំងដោយផ្ទាល់ លោកអ្នកត្រូវប្រាកដថាលោកអ្នកបានមានឯកសារចាំបាច់គ្រប់គ្រាន់។ សូមចូលមើលបញ្ជីឯកសារដែលត្រូវការដើម្បីបំពេញពាក្យ នៅទីនេះ។
សម្រាប់ការចូលមើលទីតាំងនិងទទួលសេវាផ្តល់ជំនួយ សូមចូលទៅកាន់តំណភ្ជាប់

lacbusinesses.aidkit.org/sl/taproviders.



# ជំហានទី 6៖ ព័ត៌មានអំពីអាជីវកម្មលោកអ្នក

- សូមបញ្ចូលអាជីវកម្មស្របច្បាប់របស់លោកអ្នកឬឈ្មោះអង្គភាពដែលមិនរកប្រាក់កម្រៃ របស់លោកអ្នក ព្រោះឈ្មោះនេះនឹងត្រូវបានចុះក្នុងបញ្ជីពន្ធឬការបញ្ចូលឯកសារផ្សេងៗ។
- សូមជ្រើសរើសថាតើអាជីវកម្មលោកអ្នកគឺជាអាជីវកម្មរកប្រាក់ចំណេញឬមិនរកប្រាក់ចំណេញ។
- សូមបញ្ចូលអាសយដ្ឋាននៃអាជីវកម្ម / អង្គភាពមិនរកប្រាក់ចំណេញរបស់លោកអ្នក (ទីតាំងត្រូវតែស្ថិតនៅក្នុងតំបន់ឡូស អេនជេឡេស) ។
- សូមបញ្ចូលប្រភេទអាជីវកម្មដែលលោកអ្នកដំណើរការ (ដោយឯករាជ្យ មិនមានការចុះបញ្ជី ភាពជាដៃគូ ឬ អិលស៊ីស៊ី (LLC)។ ល។ )
- សូមបញ្ចូលលេខ EIN របស់លោកអ្នក
- សូមបញ្ចូលលេខ SSN របស់លោកអ្នកឬ ITIN (សម្រាប់បញ្ចូលក្នុងព័ត៌ពន្ធដារនិងអត្តបញ្ជាក់អត្តសញ្ញាណ)
- សូមបញ្ជាក់ពីចំនួននិយោជិកដែលលោកអ្នកមាន (អាចមាន 100នាក់ ឬតិចជាងនេះ) ។
- សូមបញ្ចូលប្រាក់ចំណូលប្រចាំឆ្នាំរបស់លោកអ្នកសម្រាប់ឆ្នាំ 2023 និង 2024 ។



# ជំហានទី 7៖ សំណួរអំពីអាជីវកម្មដែលរកប្រាក់កម្រៃ និងអង្គភាពមិនរកប្រាក់កម្រៃ

សូមឆ្លើយសំណួរដែលបានផ្តល់ជូនពីប្រវត្តិនៃអាជីវកម្ម




សូមឆ្លើយសំណួរដែលបានផ្តល់ជូនពីប្រវត្តិនៃអង្គភាពមិនរកប្រាក់កម្រៃលោកអ្នក



# ជំហានទី 8៖ ផ្ទៀងផ្ទាត់ផលប៉ះពាល់ពីគ្រោះមហន្តរាយ

- សូមជ្រើសរើសពីការរងផលប៉ះពាល់លើអាជីវកម្មឬអង្គភាពមិនរកប្រាក់ចំណេញរបស់លោកអ្នក (ការខូចខាតខាងលើសំណង់អាគារ ការបាត់បង់ប្រាក់ចំណូល ការខូចខាតលើឧបករណ៍ប្រើប្រាស់។ ល។ ) ។
- សូមបញ្ចូលការប៉ាន់ស្មានលើចំនួនប្រាក់នៃការខាតបង់ប្រាក់ចំណូលបើប្រៀបធៀបវាទៅនឹងមធ្យមភាគនៃប្រាក់ចំនូលលោកអ្នកនៅឆ្នាំ 2024 ក្នុងខែដដែលដូចទៅនិងខែដែលបានរងផលប៉ះ ពាល់។
- សូមបង្ហោះឯកសារដើម្បីបង្ហាញពីផលប៉ះពាល់ពីផលប៉ះពាល់ដូចជាការទាមទារនូវកាធានារ៉ាប់រង រូបថត ឬរបាយការណ៍ប្រាក់ចំណូលផ្សេងៗ។



# ជំហានទី 9៖ ការប្រមូលឯកសារ

នៅក្នុងផ្នែកនេះ លោកអ្នកនឹងត្រូវបានស្នើសុំឱ្យធ្វើការ បង្ហោះឯកសារ ដើម្បីធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណនិងអាជីវកម្មរបស់លោកអ្នក។

អត្តសញ្ញាណ

- សូមបញ្ចូលរូបថតនៃលេខសម្គាល់អត្តសញ្ញាណដែលផ្តល់ជូនដោយរដ្ឋាភិបាលដើម្បីធ្វើការផ្ទៀងផ្ទាត់ភាពជាម្ចាស់អាជីវកម្មឬភាពជាអ្នកដឹកនាំដែលមិនរកប្រាក់ចំណេញ។
- ឯកសារដែលអាចទទួលយកបានរួមមាន៖
  - ប័ណ្ណបើកបរ (ទោះបីជាផុតកំណត់រហូតដល់ 2 ឆ្នាំ)
  - អត្តសញ្ញាណប័ណ្ណរបស់ជាជនជាតិអាមេរិច
  - លិខិតឆ្លងដែន (សហរដ្ឋអាមេរិក ឬ បរទេស)
- ព័ត៌មានដែលយើងត្រូវការត្រួតពិនិត្យ៖ ត្រូវបានថាឈ្មោះនិងរូបថតរបស់លោកអាចមើលឃើញបានច្បាស់ល្អ។

ដើម្បីពិនិត្យមើលបញ្ជីនៃឯកសារដែលត្រូវការចាំបាច់ សូមចុច នៅទីនេះ។



# ជំហានទី 9៖ ការប្រមូលឯកសារ

ដើម្បីបញ្ចប់ការផ្ទៀងផ្ទាត់អត្តសញ្ញាណអ្នកនឹងទទួលបានការថតរូបផ្ទាល់ដោយខ្លួនលោកអ្នក។ លោកនឹងទទួលបាន តំណភ្ជាប់ដែលបានផ្ញើទៅលោកអ្នកតាមសារ អ៊ីម៉ែល ឬ លោកអ្នកក៏អាចបំពេញវាដោយប្រើប្រាស់កុំព្យូទ័ររបស់ លោកអ្នកផងដែរ។






# ជំហានទី 9៖ ការប្រមូលឯកសារ

អាជីវកម្ម

- សូមធ្វើការបង្ហោះឯកសារដើម្បីបញ្ជាក់ថាអាជីវកម្មលោកអ្នកនៅមានដំណើរការនិងនៅមានជំហល្ម។
- ឯកសារដែលទទួលយកបានត្រូវតែមានការបរិច្ឆេទជាក់លាក់និងត្រូវ បានធ្វើបច្ចុប្បន្នភាព។ ក្នុងនោះរួមមាន៖
    - សម្រាប់អង្គភាពរកប្រាក់ចំណូល
        - អជ្ញាបណ្ណអាជីវកម្ម
        - មាត្រានៃការដាក់បញ្ចូល (សម្រាប់សាជីវកម្មនិង LLCs) ។
        - កិច្ចព្រមព្រៀងភាពជាដៃគូ (សម្រាប់ភាពជាដៃគូ) ។
        - ទម្រង់ IRS 941 (ដើម្បីផ្ទៀងផ្ទាត់ចំនួនបុគ្គលិក) ។
            - ចំណាំ: អាជីវកម្មទាំងឡាយណាដែលមិនមានបុគ្គលិក មិនតម្រូវចាំបាច់ក្នុងការបង្ហោះទម្រង់ពាក្យ IRS 941 នោះទេ។

សម្រាប់អង្គភាពមិនរកប្រាក់កម្រៃ

- សូមធ្វើការបង្ហោះសំណៅឯកសារភស្តុតាងពីការលើកលែងពន្ធ(IRS determination letter).
- សូមបញ្ចូលឯកសារនៃការកិច្ចសហប្រតិបត្តការពីអង្គភាពមិនរកប្រាក់ចំណេញរបស់លោកអ្នក។
- សូមផ្តល់នូវបញ្ជីក្រុមប្រឹក្សាភិបាលនិងរចនាសម្ព័ន្ធភាពនៃថ្នាក់ដឹកនាំក្នុងអង្គភាព។
- សូមបង្ហោះ ទម្រង់ពាក្យ IRS 990 ឬឯកសារហិរញ្ញវត្ថុសមមូលដើម្បីធ្វើការផ្ទៀងផ្ទាត់ប្រាក់ចំណូលនិងប្រាក់ចំណាយលើប្រតិបត្តិការនិងចំនួននៃនិយោជិក។
- ព័ត៍មានដែលយើងត្រូវការត្រួតពិនិត្យ៖ ឈ្មោះអាជីវកម្មរបស់លោកអ្នក ព័ត៍មានលំម្អិតពីការចុះឈ្មោះនិងស្ថានភាពនៃការអនុលោម។

សម្រាប់បញ្ជីនៃឯកសារសំខាន់ សូមចុចលើតំណភ្ជាប់ នៅទីនេះ



# ជំហានទី 10៖ ឯកសារផ្សេងៗពីអាជីវកម្មរកប្រាក់ចំណេញនិងមិនរកប្រាក់ចំណេញ

នៅក្នុងផ្នែកនេះ លោកអ្នកនឹងត្រូវបានស្នើអោយធ្វើការបង្ហោះឯកសារបន្ថែមដែលបញ្ជាក់បន្ថែមលើប្រភេទនៃអាជីវកម្មលោកអ្នក (រកប្រាក់ចំណេញ vs មិនរកប្រាក់ចំណេញ).

## Nonprofit




## For Profit



# ជំហានទី 11៖ ភស្តុតាងនៃការរងផលប៉ះពាល់លើអាជីវកម្ម

- សូមបង្ហោះឯកសារផ្លូវការមួយដែលបង្ហាញពីអាសយដ្ឋានអាជីវកម្មរបស់លោកអ្នក។ ឯកសារនេះនឹងត្រូវបានប្រើដើម្បីផ្ទៀងផ្ទាត់ថាអាជីវកម្មរបស់លោកអ្នកពិតជាមានទីតាំងស្ថិតនៅក្នុងតំបន់ដែលបានរងផលប៉ះពាល់ក្នុងអំឡុងពេលមានគ្រោះមហន្តរាយនេះ។
- ឯកសារដែលទទួលបានរួមមាន៖
  - ឯកសារទាមទារពីបណ្ណធានារ៉ាប់រង
  - រូបថតនៃបំណែកខូចខាងនៅក្នុងទ្រព្យសម្បត្តិ ឬ សម្ភារៈ
  - របាយការណ៍នៃការខាតបង់ប្រាក់ ឬ ឯកសារបញ្ជាក់ផ្នែកហិរញ្ញវត្ថុ
  - របាយការណ៍ពីមន្ត្រីប៉ូលីស ឬលិខិតបញ្ជាក់ពី FEMA (FEMA determination letter)
- ព័ត៌មានដែលយើងត្រូវការត្រួតពិនិត្យ៖
  - ឈ្មោះអាជីវកម្មនិងអាស័យដ្ឋានផ្ទាល់របស់លោកអ្នក។ ព័ត៌មាននេះត្រូវតែត្រូវដូចគ្នាជាមួយនឹងឈ្មោះនិងអាសយដ្ឋានផ្ទាល់ដែលបានបញ្ចូលពីមុននៅក្នុងព័ត៌មាននៃការដាក់ពាក្យ។

សម្រាប់បញ្ជីនៃឯកសារសំខាន់ សូមចុចលើតំណភ្ជាប់ នៅទីនេះ។


Previous: Additional Business Document Collection

## Impact From Disaster Documents

**To verify the impact of the disaster on your business, please upload ONE document that includes the business name and physical address. Acceptable documents include (but are not limited to):**

**If you are leasing the property from which your business operates:**

- Lease or Rental Agreement

**If you own the property from which your business operates:**

- Grant Deed
- County Recorder Documentation
- Ownership Affidavit
- Business or Property Ownership Documentation
- Property Tax Documents
- Business License or Permit
- Articles of Incorporation or Business Registration Documents
- Official Documents Filed with a State Agency

**You may also provide additional documents to further verify the disaster's impact, such as:**

- FEMA Determination Letter
- Photos of damages to property or equipment located in emergency zones
- Police report, news clips, or other supporting documentation

## ជំហានទី 12៖ ត្រួតពិនិត្យឡើងវិញReview

- សូមធ្វើការពិនិត្យដោយប្រុងប្រយ័ត្នរាល់ព័ត៌មានដែលលោកអ្នកបានបញ្ចូលព័ត៌មានដែលថាវាជាព័ត៌មានដែលត្រឹមត្រូវ។
- សូមប្រាកដថាលោកអ្នកបានធ្វើការបង្ហោះរាល់ឯកសារដែលចាំបាច់ទាំងអស់។
- សូមបញ្ចប់ការបញ្ជាក់ ដោយប្រាកដថាព័ត៌មានដែលលោកអ្នកបានបញ្ចូលគឺពិតនិងត្រឹមត្រូវ។

សម្រាប់បញ្ជីនៃឯកសារសំខាន់ សូមចុចលើតំណភ្ជាប់ នៅទីនេះ។



# ជំហានទី 13 - [មិនតម្រូវចាំបាច់] ចែករំលែកពីសាច់រឿងរបស់លោកអ្នក

The City and County of Los Angeles are working hard to raise funds to support people who have been affected by the LA Windstorm and Wildfire Emergency. If you'd like to share how this emergency has impacted you, your story can help others understand the need in your community. Sharing is completely optional and will not affect your eligibility for this program. If we need more details, we may reach out to you.

# Step 14: Submit Your Application

- Click "Submit" once everything is reviewed.

- After submission, you will receive an email confirming your application status.




department of economic opportunity
COUNTY OF LOS ANGELES

ECONOMIC & WORKFORCE DEVELOPMENT DEPARTMENT LOS ANGELES

# ជំនួយក្នុងការដាក់ពាក្យស្នើសុំនិងសុំជំនួយ

💡លោកអ្នកត្រូវការជំនួយមែនទេ? ប្រសិនបើលោកអ្នកត្រូវការជំនួយក្នុងការបំពេញពាក្យស្នើសុំ ឬមានសំណួរផ្សេងៗ លោកអ្នកអាចធ្វើការទាក់ទងទៅកាន់ក្រុមជំនួយ ព័ត៍មាន Aidkit៖

📞ផ្ញើសារឬការហៅតាមទូរស័ព្ទ (323)701-1591 ឬ
📧អ៊ីម៉ែល sucep@lacworkers.aidkit.org

សម្រាប់ទីតាំងនិងជំនួយផ្នែកព័ត៍មាន សូមចូលទៅកាន់គេហទំព័រ lacbusinesses.aidkit.org/sl/taproviders.

department of economic opportunity
COUNTY OF LOS ANGELES

ECONOMIC & WORKFORCE DEVELOPMENT DEPARTMENT
LOS ANGELES

# ការរំលឹកចុងក្រោយ

✅ ការបិទពាក្យស្នើសុំនឹងត្រូវបញ្ចប់ត្រឹមថ្ងៃទី 24 ខែកុម្ភៈឆ្នាំ 2025 ។

✅ មូលនិធិមានចំនួនកំណត់។

✅ សូមតាមដានព័ត៌មានថ្មីៗ ពីព័ត៌មានបច្ចុប្បន្នភាពដែលត្រូវបានផ្ញើជូនតាមរយៈអ៊ីមែលឬការផ្ញើសារ។

**តាមរយៈការអនុវត្តតាមការណែនាំខាងលើនេះ លោកអ្នកនឹងយល់ច្រើនអំពីតម្រូវការនិងលក្ខខណ្ឌ និងដំណើរការនៃការដាក់ពាក្យស្នើសុំ។ ប្រសិនបើលោកអ្នកមានចម្ងល់ផ្សេងៗ សូមស្វែងរកជំនួយពីក្រុមការងារផ្តល់ព័ត៌មាន!**